**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ខែ ឆ្នាំ ២០១១

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Dec-2011, 12:24
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការគាំទ្រមួយផ្នែករបស់ អៀង សារី ចំពោះសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យមានការគ្រប់គ្រងសវនាការ**

---

| <u>ដាក់ដោយ</u>៖ | <u>ផ្ញើជូន</u>៖ | <u>ផ្ញើជូន</u>៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម យូរ ឧត្តរ៉ា | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | **ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| | ចៅក្រមបំរុង ធូ មណី | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្ដី”) តទៅនេះសូមគាំទ្រមួយផ្នែកដល់សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យមានការគ្រប់គ្រងសវនាការ[1] ។ កសព ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង: ១)ដាក់ចេញនៅមុនថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ នូវដីកាបណ្ដោះអាសន្នសម្រាប់សាក្សី និង ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងផ្នែកដំបូងនៃការជំនុំជម្រះក្ដីនៅដំណាក់កាលទី១។ កំណត់វិសាលភាព និងពេលវេលានៃផ្នែកទីពីរ និងកំណត់អត្តសញ្ញាណសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីសក្ខីកុពល សម្រាប់ផ្នែកទីពីរនេះយ៉ាងហោចណាស់សម្រាប់រយៈពេលដែលគ្របដណ្ដប់ក្នុងកិច្ចជំនុំជម្រះនៅដំណាក់កាលទីពីរ គឺនៅថ្ងៃទី១០ ខែមករា ដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១”, ២) ដកឈ្មោះអ្នកជំនាញមួយរូប និងសាក្សីបួនរូប ដែលពាក់ព័ន្ធទៅនឹង អៀង ធីរិទ្ធ និង៣) ផ្ដល់រយៈពេលមួយសប្ដាហ៍សម្រាប់សវនាការ ក្នុងគោលបំណងផ្ដល់សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ស្ដីពីការទទួលយកឯកសាររយៈពេលប្រាំថ្ងៃ ក្នុងអំឡុងពេលពីថ្ងៃទី៦ ដល់ថ្ងៃទី៩ ខែកុម្ភៈឆ្នាំ២០១២[2] ។ មេធាវីការពារសូមគាំទ្រទាំងស្រុងដល់សំណើទី១ ។ វាមានសារៈសំខាន់ណាស់ចំពោះភាគីដែលត្រូវទទួលបានព័ត៌មានឲ្យបានឆាប់ តាមតែអាចធ្វើបាន ដើម្បីត្រៀមលក្ខណៈរៀបចំឲ្យបានគ្រប់គ្រាន់សម្រាប់សវនាការ ។ មេធាវីការពារក្ដីមិនមានជំហរអ្វីនៅពេលនេះទេ ទាក់ទងនឹងសំណើទីពីរនោះ ។ ចំពោះសំណើទីបីវិញ មេធាវីការពារក្ដីយល់ស្របថាវាជាការសំខាន់ក្នុងបែងចែកពេលវេលាសម្រាប់ការធ្វើសន្និដ្ឋានផ្ទាល់មាត់ពាក់ព័ន្ធនឹងការទទួលយកឯកសារឲ្យបានឆាប់ បន្ទាប់ពីដំណើរការនីតិវិធីជំនុំជម្រះចាប់ផ្ដើមជាថ្មី ប៉ុន្ដែ មេធាវីការពារក្ដីយល់ឃើញថារយៈពេលមួយសប្ដាហ៍ គឺវាគ្រប់គ្រាន់សម្រាប់ពិចារណាលើការទទួលយកឯកសាររបស់ កសព ចំនួន ៤.៧៦៨ ឯកសារ និងឯកសារជាង ៧000 របស់ដើមបណ្ដឹងរដ្ឋប្បវេណី ។

**អាស្រ័យដូចបានបញ្ជាក់ក្នុងមូលហេតុខាងលើ** សូមលោក/លោកស្រីចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្ដីគោរព។

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យមានការគ្រប់គ្រងសវនាការជំនុំជម្រះ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១, E153 ។

[2] ដូចខាងលើ នៅកថាខណ្ឌទី១ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ខែ ឆ្នាំ ២០១១

___________________ ___________________

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**